# ការសម្ភាសន៍របស់បងប្រុស គង់ ថុល

កៈ អ្នកសម្ភាសន៍មាន រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍មានឈ្មោះថា គុង ថុល

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងប្រុស គុង ថុល</u>

ការសម្ភាសន៍ជីវប្រវត្តិរបស់បងប្រុស គង់ ថុល
គាត់មានការតស៊ូតាំងគាត់នៅតូចរហូតមកដល់ធំហើយគាត់អត់មានឪពុកមកថែរក្សាគាត់ទេហើយគាត់មានតែម្តាយរបស់គាត់ធ្វើជាអង្គទាំងពីគឺលោកឪពុកផងនិងធ្វើជាអ្នកម្តាយផងគាត់ហើយគាត់ខំប្រឹងរកលុយចិញ្ចឹមប្អូនៗរបស់គាត់យ៉ាងលំបាក។ដោយគាត់ខំប្រឹងទៅធ្វើការឲ្យគេផងនិងធ្វើការខ្លួនឯងផងដោយគាត់ទៅបេះក្រហ្មារឈូកយកទៅលក់។ហើយគាត់ជាមនុស្សស្លូតបូតហើយមានការរាក់ទាក់មានសេចក្តីមេត្តាហើយមានការរសរាយផងដែរ។ធ្វើឡើងនៅភូមិបឹងសាឡាង សង្កាត់ ឬស្សីកែវ ខ័ណ្ឌ ឬស្សីកែវ ភ្នំពេញ
ធ្វើឡើងនៅថ្ងៃទី ១០ ខែ ០៥ ឆ្នាំ ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរបងប្រុសខ្ញុំបាទឈ្មោះថា រត្ន ពិសីហើយដោយសូមអនុញ្ញាតបងប្រុសធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់បងប្រុស។ហើយខ្ញុំធ្វើឡើងដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាសាកលវិទ្យាល័យ “ B Y U “ ដែរមានទីតាំងនៅសហរដ្ឋអាមេរិចបងប្រុសហើយដើម្បីថែរក្សាជីវប្រវត្តិរបស់បងប្រុសហើយដើម្បីថែរក្សាជីវប្រវត្តិរបស់ដូនតារបស់បងប្រុស។ហើយទុកឲ្យកូនចៅជំនាន់ក្រោយបានស្តាប់ថាអ្នកជំនាន់មុនមានការលំបាកហើយបានឆ្លងកាត់ឧបសគ្គអ្វីខ្លះនៅក្នុងជីវិតរបស់ពួកគាត់អញ្ចឹងបងប្រុសហើយខ្ញុំធ្វើឡើងនៅថ្ងៃទី ១០ ខែ ០៥ ឆ្នាំ ២០១៨ ។ហើយអញ្ចឹងអត់ទោសបងនៅគេហៅភូមិអីគេដែរបងប្រុស?

ខៈ ចឹងនិយាយពីស្រុកកំណើតមែន?

កៈ នៅនិងបងនៅភូមិអីអញ្ចឹងបង។

ខៈ ហើយចង់និយាយពីស្រុកកំណើតម៉ងទៅ។

កៈ អត់ទេបងនៅនិងម៉ងបង។

ខៈ ហើយបើនិយាយពីឥឡូវវាពិបាកបន្តិចបើយើងពីដើមមកវិញវាស្រួលបន្តិច។

កៈ បាទ!

ខ៖ ហើយបើយើងនិយាយពីស្រុកកំណើតមកវិញអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងបងស្រុកកំណើតនៅណាវិញបង។

ខ៖ ខ្ញុំនៅកំពង់ចាម។

ក៖ បាទ! ហើយអញ្ចឹងនៅភូមិអីគេដែរបង?

ខ៖ នៅឯភូមិជំទាវជំក្រប ឃុំ រំចេក ស្រុក កំពង់សៀម ខេត្ត កំពង់ចាម ។

ក៖ បាទ! បងអ្នកស្រុក
កំពង់ចាមបងណោះ។ហើយអញ្ចឹងបងនៅបច្ចុប្បន្ននិងនៅភូមិអីដែរបង?

ខ៖ ខ្ញុំនៅបច្ចុប្បន្ននិងគេហៅបឹងសាឡាង ខ័ណ្ឌ ឫស្សីកែវ ភ្នំពេញ។

ក៖ ហើយអញ្ចឹងបងមានឈ្មោះអីគេដែរបង?

ខ៖ ខ្ញុំឈ្មោះគង់ ថុល ។

ក៖ ហើយអញ្ចឹងបងមានអាយុប៉ុន្មានដែរបងប្រុស?

ខ៖ ខ្ញុំមានអាយុ៤១ឆ្នាំ។

ក៖ បាទ! ហើយអញ្ចឹងបង៤១ឆ្នាំថ្មីនិងបងប្រុស។ហើយអញ្ចឹងបងមានចាំថ្ងៃ ខែ
ឆ្នាំកំណើតរបស់បងប្រុសទេ?

ខ៖ ខ្ញុំអត់ចាំថ្ងៃ ខែទេតែខ្ញុំចាំឆ្នាំ១៩៧៨និង។

ក៖ បាទ! បងកើតនៅឆ្នាំ១៩៧៨បង។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងទីកន្លែងកំណើតរបស់បងនៅឯណា?

ខ៖ បើទីកំណើតនិងនៅភូមិជំទាវជំក្របនិង។

ក៖ បាទ! បងកំណើតនៅនិងម៉ង។ហើយអញ្ចឹងបងមានឈ្មោះហៅក្រៅទេបង?

ខ៖
ហើយបើគេហៅក្រៅនិងបើនៅស្រុកនិងហើយបើនៅភ្នំពេញនិងគេហៅគ្រូក្មេងៗហើយគ្រូ
ថ្នាំខ្មែរៗហើយបើគេអ្នកស្គាល់ជិតដិតបានគេហៅឈ្មោះចំថុលៗអញ្ចឹងណាស់។

កៈ បាទ!

ខៈ
ហើយខ្ញុំនៅស្រុកកំណើតខ្ញុំនិងខ្ញុំបង្កើតតាំងពីសូន្យមកហើយខ្ញុំបែកពីឪពុកខ្ញុំហើយឪពុកខ្ញុំទៅបាត់ទៅណាស់។

កៈ បាទ !ៗ

ខៈ ហើយបាត់ប្រហែលជា១៦ឆ្នាំបាត់ចោលខ្ញុំ។

កៈ បាទ!

ខៈ
គាត់ទៅបាត់១៦ឆ្នាំហើយពេលបានមកជួបខ្ញុំប្រហែលជា៩ទៅ១០គាត់បានស្លាប់ចោលខ្ញុំទៅ។

កៈបាទ!

ខៈ បើប្រហែលជាឥឡូវនិងប្រហែល៩ទៅ១០ឆ្នាំហើយ។

កៈ បាទ!

ខៈ
ហើយដល់ពេលអញ្ចឹងទៅខ្ញុំពិបាកណាស់ហើយខ្ញុំកាលដើរប្រកបមុខរបរដើរដកក្របហ្គារឈូកបេះឈូកអញ្ចឹងទៅណាស់។

កៈ បាទ!

ខៈ ហើយដើរទៅបេះត្រកួនទៅហើយពេលនិងគ្មានមុខរបរអីរកទេកាលនិងនោះ។

កៈ បាទ! ហើយអញ្ចឹងបងបើនិយាយពីឆ្នាំខ្មែរយើងនិងបងកើតឆ្នាំអីគេដែរបង?

ខៈ ឆ្នាំខ្មែរនិងខ្ញុំកើតក្រោយចូលឆ្នាំខ្មែរនិងខែ០២។

កៈ ដូចឆ្នាំខ្មែរយើងបង។

ខៈ ឆ្នាំខ្មែរយើងនិង។

កៈ បាទ! ដូចជា ជូត ឆ្លូវ ខាល  ថោ អញ្ចឹងបង?

ខៈ ហើយអានឹងប្រហែលជាអរនិយាយរឿងឆ្នាំខ្មែរ។

ក៖ បាទ!

ខ៖ ឆ្នាំខ្មែរដូចជាឆ្នាំ មមីរ ។

ក៖ អរបងឆ្នាំ មមីរបង។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងប្អូនបង្កើតរបស់បងមានប៉ុន្មាននាក់ដែរបង?

ខ៖ បងប្អូនខ្ញុំមានប្រាំមួយនាក់។

ក៖ អរប្រាំមួយបងណោះ។

ខ៖ បាទ!

ក៖ ហើយប្រុសប៉ុន្មានស្រីប៉ុន្មានដែរបង?

ខ៖ អូរបងប្អូនខ្ញុំប្រាំនាក់។

ក៖ ប្រាំនាក់។

ខ៖ ហើយស្លាប់ម្នាក់នៅសល់តែប្អូនទេ។

ក៖ បាទ! ហើយស្រីប៉ុន្មានប្រុសប៉ុន្មានដែរបង?

ខ៖ ស្រីតែមួយតា។

ក៖ ហើយអញ្ចឹងប្រុសបីបងណោះ។

ខ៖ បាទ!

ក៖ ហើយអ្នកដែរស្លាប់និងស្រីក៏ប្រុសដែរបង?

ខ៖ អ្នកដែរស្លាប់និងប្រុស។

ក៖
ហើយអញ្ចឹងបងប្អូនបងប្រុសបីស្រីមួយណាបងណោះ។ហើយអ្នកដែរស្លាប់និងប្រុសក៏ស្រីបង?

ខ៖ ប្រុស។

កៈ ហើយគាត់ស្លាប់បានប៉ុន្មានឆ្នាំហើយបង?

ខៈ គាត់ស្លាប់តាំងពីឆ្នាំ១៩៩៤។

កៈ អរគាត់ស្លាប់១៩៩៤ហើយអញ្ចឹងគាត់ស្លាប់ដោយសារអីដែរបង?

ខៈ គាត់ដោយសារហើយបើនិយាយឲ្យចង់ទៅគេហៅជម្ងឺគ្រុនឈាម។

កៈ អរជម្ងឺគ្រុនឈាមជំនាន់និង។

ខៈ អត់មានពេទ្យហើយអត់សូវមានពេទ្យពូកែព្យាបាលនិង។

កៈ បាទ! ហើយអញ្ចឹងបងមានចាំថាបងជាកូនទីប៉ុន្មានដែរបង?

ខៈ ខ្ញុំកូនទីពីរ។

កៈ បាទ! បងកូនទីពីរ។ហើយអញ្ចឹងបងប្រុសរបស់បងមានឈ្មោះអីគេដែរបង?

ខៈ គាត់នៅឈ្មោះ ថុយ។

កៈ គាត់ឈ្មោះ ថុយ។គាត់អត់នៅនិងទេបងឬគាត់នៅស្រុកកំណើតបង។

ខៈ គាត់នៅឯជ្រាយចង្វា។

កៈ អរគាត់នៅជ្រាយចង្វា។

ខៈ បាទ!

កៈ ហើយអញ្ចឹងប្អូនប្រុសបងបន្ទាប់ពីបងមានឈ្មោះអីគេដែរបង?

ខៈ ប្អូនប្រុសខ្ញុំបន្ទាប់ពីខ្ញុំនិងគាត់ស្លាប់និងមែន។

កៈ អត់បន្ទាប់ពីបង។

ខៈ អរស្រី។

កៈ ហើយគាត់មានឈ្មោះអីគេដែរបង?

ខៈ ឈ្មោះ ខេង។

កៈ អរឈ្មោះ ខេង។ហើយអញ្ចឹងបន្ទាប់មកទៀតបង?

ខ៖ ឈ្មោះ ខៀង។

ក៖ ហើយអញ្ចឹងអ្នកស្លាប់និងមានឈ្មោះអីគេដែរបង?

ខ៖ អ្នកស្លាប់និងឈ្មោះ ថុង ។

ក៖ បាទ! អ្នកស្លាប់និងមានឈ្មោះ
ថុង។ហើយអញ្ចឹងគាត់ដែរស្លាប់និងគាត់ទីប៉ុន្មានដែរបង?

ខ៖ ទីបី។

ក៖ អរទីបីបន្ទាប់ពីបង។

ខ៖ និងហើយៗ។

ក៖
ហើយអញ្ចឹងបងមានចាំសាច់រឿងបងជាមួយពួកគាត់ទេបង?ដូចថាធ្លាប់ធ្វើអីជាមួយគ្នាហើយធ្លាប់ពិបាកជាមួយគ្នាអីអញ្ចឹងណាស់។

ខ៖
អរបើនិយាយពីប្រវត្តិបើកាលពីនៅក្មេងនិងខ្ញុំពិបាកជាមួយគាត់ណាស់ដូចថាម្តាយខ្ញុំគាត់ដូចបេះល្ហុងទៅលក់នៅផ្សារនិងទៅអញ្ចឹងណាស់ហើយខ្ញុំជាមួយពួកគាត់នាំគ្នាទៅដកក្របាវឈូកអញ្ចឹងណាស់បេះត្រកួនហើយបេះប្រលិតយកមកអញ្ចឹងណាស់បើខាងនិងវាអត់មានមុចរបរអីរកអញ្ចឹងណាស់មានតែប្រើកម្លាំងធ្វើស្រែប្រាំងអញ្ចឹងទៅ។

ក៖ បាទ! ទៅធ្វើស្រែប្រាំងអញ្ចឹងទៅ។

ខ៖ បាទ!
ហើយស្រែធ្វើចំការនិងហើយដាំឈូកហើយមកដល់បច្ចុប្បន្ននិងក៏មានគេដាំឈូកដែរហើយអត់ថាមានមុខរបរណារកទេ។

ក៖ បាទ!
ហើយអញ្ចឹងធ្លាប់កំសត់ជាមួយគ្នាហើយធ្លាប់លំបាកជាមួយគ្នាអញ្ចឹងទៅបងប្រុស?

ខ៖ បាទ!
ហើយវានៅស្រុករាល់ថ្ងៃនិងហើយបើរាល់ថ្ងៃនិងបើនៅភ្នំពេញយើងឥឡូវក៏មិនស្រួលដែរ។

ក៖ បាទ!

ខ៖
បើមកយើងគិតឃើញយើងមកអត់មានលុយមានកាកមកហើយពិបាកណាស់ហើយទម្រម
ថាបានមួយលក់ថ្នាំអីអញ្ចឹងទៅណាស់។

ក៖ បាទ!

ខ៖ ហើយពីខ្លះយើងមកនិងយើងដកបន្លែ
ក្រហ្មារឈូកអញ្ចឹងមកយកលក់ទៅហើយបានខ្ញុំតស៊ូជាមួយនិងផ្ទះជួលនិងប្រហែលជាបីបួ
នឆ្នាំ។

ក៖ បាទ! បងបាទ។

ខ៖
បានបីបួនឆ្នាំហើយខ្ញុំចេះតែតស៊ូទៅហើយបានសន្សំលុយបានទិញដីនៅនោះបានមួយក
ន្លែងទៅហើយតារាល់ថ្ងៃនិងយើងអត់ទាន់មានលុយអញ្ចឹងណាស់ហើយយើងអត់មានលុ
យធ្វើផ្ទះអីអញ្ចឹងណាស់។

ក៖ បាទ! បង បាទ។

ខ៖ ហើយយើងកុំប្រឹងរកអីខ្លះហើយយើងជំពាក់គេអីខ្លះទៅណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយបានដីអីនៅអញ្ចឹងណាស់។

ក៖ បាទ! រាល់ថ្ងៃនិងបើយើងមិនជំពាក់គេមិចបានរបស់បង?

ខ៖ បាទ!
ហើយរាល់ថ្ងៃនិងតស៊ូជាមួយផ្ទះជួលនិងហើយរាល់ថ្ងៃនិងលំបាកដែរហើយថ្លៃទឹកថ្លៃភ្លើង
ហើយស៊ីចាយហើយពេលខ្លះយើងលក់ថ្នាំដាច់អញ្ចឹងទៅ។

ក៖ ហើយយើងបានធូរធារដែរ។

ខ៖ បាទ!
ហើយថ្ងៃណាយើងរកបានហើយជួនកាលរកអត់បានអញ្ចឹងទៅណាស់ហើយប្រពន្ធខ្ញុំអត់
មានការងារធ្វើទេរាល់ថ្ងៃនិងរោងចក្រនិងគេរំសាយចោលអញ្ចឹងណាស់។

ក៖ បាទ! គេរំសាយរោងចក្រនិងគេមិចបង?

ខ៖ គេរំសាយដូចអត់ដឹងថាថ្ងៃណាគេរើសវិញវាអត់មានការងារធ្វើណាស់។

ក៖ អរគេទុកតែបុគ្គលិតចាស់ៗទេបង។

ខ៖
អត់ទេគាត់បុគ្គលិតគេយូរឆ្នាំដែរនិងដូចថាគេហើយឥឡូវរកការងារធ្វើអត់ទាន់បានហើយពិបាកការងារធ្វើណាស់។

ក៖ បាទ!

ខ៖ ដូចខ្ញុំនេះអញ្ចឹងផុតពីលក់ថ្នាំហើយយើងអត់មានការងារក្រៅធ្វើអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
គ្មានការងារណាធ្វើទេរាល់ថ្ងៃនិងហើយការងារយើងត្រូវធ្វើមានតែការងារសំណង់និងហើយនិងការងារក្រៅហើយនិង។

ក៖ បាទ! និងគេហៅការងារក្រៅហើយនិង។

ខ៖ បាទ!
ហើយដូចការងារស្រុកខ្មែរមានអីរកមានតែម៉ូតូមួយរត់ឌុបនិងទៅយើងមានមុខរបរអីយើងអត់ចេះអក្សរនិង។

ក៖ បាទ!

ខ៖ ហើយបើយើងបានរៀនពីជំនន់និងមកហើយយើងរៀនអត់បានខ្ពង់ខ្ពស់។

ក៖ បាទ!

ខ៖
ហើយបើសិនយើងមានហើយស្រុកយើងមានសិប្បកម្មអីហើយដូចមានមុខរបរអីរកការងារស្រួលហើយអូនឯងនិង។

ក៖ បាទ!

ខ៖
ហើយតែវាអត់មានហើយអញ្ចឹងប្រាក់ចំនូលរបស់យើងវាពិបាកដែរពិបាកខ្លាំងតែម្ដងនិង

ហើយរាល់ថ្ងៃយើងគិតមើលទៅថ្លៃផ្ទះថ្លៃទឹកថ្លៃភ្លើងស៊ីចាយហើយផ្តល់ឲ្យម្តាយហើយចិញ្ចឹមចៅអីពិបាកណាស់។

កៈ បាទ!

ខៈ វាគ្មានពេលទេ។

កៈ បាទ! ហើយអញ្ចឹងពេលបងនៅក្មេងហើយនិងបងប្អូនរបស់បងចូលចិត្តធ្វើអីគេដែរបង?

ខៈ
បើនិយាយចំទៅនៅពីក្មេងបើចូលចិត្តនិងបើនៅស្រុកកំណើតនិងគ្មានអីគ្មានអីទេចូលចិត្តរកស៊ីហើយទៅធ្វើការនិងហើយពេលទំនេរមានអីទៅបឹងទៅបេះស្លឹកឈូកនិងហើយកាលនិងគេអត់ទាន់ប្រើថង់ទេគេប្រើស្លឹកឈូកនិង។

កៈ បាទ! ហើយទូលមកអញ្ចឹង។

ខៈ បាទ!
ទូលមកដាក់ក្រមាទូលមកស្លឹកឈូកនិងទៅហើយរៀបស្លឹកឈូកយើងម៉ាសាយនិងទៅដាក់ចាន់និងទៅហើយទៅលក់និងទៅ។

កៈ បានយកទៅលក់នៅផ្សារបឹងកុកយើងនិងមែនបង។

ខៈ
បាទ!ផ្សារបឹងកុកយើងនិងហើយចេះតែរកបណ្តើមៗហើយម្តាយនិងគាត់ចេះតែដឹកបន្លែទៅផ្សារទៅ។

កៈ បាទ! ហើយអញ្ចឹងពេលនិងអត់ចិញ្ចឹមជ្រូកចិញ្ចឹមទាអីទេបង?

ខៈ
អរបើការចិញ្ចឹមជ្រូកចិញ្ចឹមទានិងយើងចិញ្ចឹមអត់បានព្រោះអីយើងអត់មានបទពិសោធន៍ហើយពិបាករកហើយនិយាយទៅពិបាកគ្រប់សព្វបែបយ៉ាងតែម្តងនិងម៉ងនិង?

កៈ បាទ!

ខៈ ហើយគិតមើលថាខាងនោះទន្លេហើយខាងនេះបឹងអត់ដឹងថារកអី។

កៈ បាទ! ហើយយើងមើលថាខាងនោះទន្លេហើយខាងនេះបឹង។

ខៈ បាទ! ហើយដីវាខ្ពីយើងដាំអីអត់កើតណាស់។

កៈ បាទ!

ខៈ វាដាំអីអត់បាន។

កៈ ហើយអញ្ចឹងបងដូចខ្ញុំបានលឺថាដីនៅខាងនិងគេដាំថ្នាំបង?

ខៈ អរគេដាំថ្នាំនិងគេដាំនៅក្រោយម្ខាង។

កៈ បាទ!

ខៈ
ហើយក្រោយម្ខាងឯណុសហើយនៅខាងហាន់ជ័យគេដាំថ្នាំគេសប្បូរដាំថ្នាំនិងហើយបើឥឡូវនិងគេអត់សូវបានដាំថ្នាំដែរនិង។

កៈ ហើយនៅនិងគេដាំអីប៉េកគួក។

ខៈ
អរគេដាំប៉េកគួកមកខាងនេះហើយគេដាំថ្នាំនៅខាងនេះដូចថាគេនៅភូមិឃុំនិងវាខុសគ្នា។

កៈ បាទ!

ខៈ
ហើយដាំដំណាំនិងចប់ហើយវាគ្មានមុខរបរអីនេះហើយតែយើងអត់ដឹងថាទៅរកអីយើងធ្វើការងារដាំនិងតិចតួចទៅណាស់។

កៈ ហើយអញ្ចឹងបងប្អូនៗបងឥឡូវគាត់រស់នៅឆ្ងាយពីគ្នាអស់ហើយបង?

ខៈ
អរបើនិយាយទៅគាត់រស់នៅឆ្ងាយពីគ្នាហើយគាត់មានមុខរបរផ្សេងៗគ្នាអស់ហើយអញ្ចឹងណាស់។

កៈ គាត់មានគ្រួសារអស់ហើយបង?

ខៈ បាទ! គ្រួសារអស់ហើយតែគាត់មានមុខរបរផ្សេងៗគ្នានិង។

កៈ បាទ!

ខៈ
ហើយអ្នកខ្លះគេរកស៊ីពីខ្ញុំអញ្ចឹងទៅគេចេះតែមកបានបន្តិចទៅហើយខ្ញុំចេះតែរកបានពីរបីឆ្នាំអញ្ចឹងទៅហើយពីរនាក់ប្តីប្រពន្ធចេះតែរកទុកទៅហើយបើឥឡូវបច្ចុប្បន្ននិងឥឡូវវាមាន

នៅផ្ទះជួលទេហើយកន្លងបានមួយឆ្នាំអីទៀតបានយើងមានផ្ទះខ្លួនឯងបាននៅអញ្ចឹងណាស់ហើយការតស៊ូបើយើងមិនតស៊ូនិងទេវាពិបាកណាស់ហើយយើងធ្វើជាមនុស្សយើងត្រូវមានការតស៊ូ។

ក៖ បាទ!

ខ៖
ជូនកាលខ្ញុំមកបន្ទប់និងជូនកាលខ្ញុំមានលុយតែដប់ម៉ឺនទេខ្ញុំមកនៅនិងហើយអ្នកខ្លះគេអត់ជឿរថាយើងមានលុយមួយម៉ឺនលុយខ្មែរទេ។

ក៖ បាទ!

ខ៖
ហើយខ្ញុំនៅសល់លុយមួយម៉ឺននិងហើយកាលខ្ញុំនៅនោះខ្ញុំរកស៊ីខាតអីអញ្ចឹងទៅហើយខ្ញុំមកនេះមកខ្ញុំនៅសល់លុយ១០ម៉ឺននិងទៅហើយចេះតែកក់គេបាន៩ម៉ឺនអីអញ្ចឹងទៅ។

ក៖ បាទ! បងចេះតែតស៊ូទៅបង។

ខ៖ បាទ! ចេះតែតស៊ូអីអញ្ចឹងទៅហើយខំប្រឹងទិញចាន់ហើយឆ្នាំងយកមកដាំទៅ។

ក៖ បាទ!ហើយអញ្ចឹងមុនបង?

ខ៖
កាលមុនគ្មានទេចាន់ឆ្នាំងនិងហើយខ្ញុំមកបានមុខដំបូងខ្ញុំបានសន្សំទិញបានធុងអង្ករហើយធុងអង្ករនិងបែកបាត់ហើយធុងអង្ករនិងហើយបោះចោលទៅក្រៅបាត់ហើយ។

ក៖ បាទ! ហើយអញ្ចឹងបងមានចាំឈ្មោះម្ដាយរបស់បងទេបង?

ខ៖ គាត់មានឈ្មោះ សុផា ។

ក៖ បាទ! ហើយចុះលោកពូឪពុកបង?

ខ៖ ឪពុកខ្ញុំគាត់ស្លាប់បាត់ហើយ។

ក៖ បាទ! ហើយអញ្ចឹងបងមានចាំឈ្មោះគាត់ទេ?

ខ៖ គាត់និងមានឈ្មោះគង់។

ក៖ គាត់ឈ្មោះ គង់បង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងម្ដាយបងមានប្រជុនប៉ុន្មានដែរបង?

ខ៖ ឥឡូវគាត់៦៨ឆ្នាំហើយ។

ក៖ បាទ! ឥឡូវគាត់នៅស្រុកនិង។

ខ៖ បាទ! គាត់នៅស្រុក។

ក៖ គាត់នៅផ្ទះធ្វើការតិចតួចទៅ។

ខ៖
គាត់នៅផ្ទះនិងគាត់ចាស់មានអាយុ៥០ទៅ៦០ឆ្នាំហើយនិងគាត់នៅស្រុកស្រែចំការហើយ
គាត់មានកម្លាំងកំហែងណា។

ក៖ ហើយអញ្ចឹងគាត់ទៅវត្តអីអញ្ចឹងទៅ។

ខ៖ បាទ!
គាត់ទៅវត្តរាល់ថ្ងៃនិង។ហើយគាត់មានអាយុច្រើនហើយនិងគាត់មានអាយុតិចណា។

ក៖ បាទ!
ហើយអញ្ចឹងបងប៉ារបស់បងគាត់មានប្រជុនប៉ុន្មានដែរបង?ពេលដែរគាត់អត់ទាន់ស្លាប់និង
បង?

ខ៖
កាលនិងគាត់ហើយបើនិយាយទៅគាត់ដូចគាត់មិនឈឺអីដែរហើយគាត់ចេះតែនិយាយប្រា
ប់ថារយៈពេលពីរឆ្នាំគាត់ស្លាប់ហើយ។ហើយគាត់ប្រាប់ថាគាត់រស់បានតែពីរឆ្នាំទៀតគាត់
ស្លាប់ហើយ។

ក៖ បាទ!ហើយអញ្ចឹងគាត់ដឹងខ្លួនគាត់ដែរបង?

ខ៖
និងហើយគាត់ដឹងហើយដែរនិងហើយគាត់ចេះតែរាប់ថ្ងៃខែគាត់ហើយគាត់រាបបានប្រាំពីរ
ហើយគាត់ថាគាត់នៅសល់តែប្រាំពីរខែទៀតគាត់ស្លាប់ហើយ។

ក៖ បាទ!

ខ៖ ហើយគាត់រាប់បានសល់មួយខែទៀតហើយគាត់រាប់ជាអាទិត្យម្ដង។

កៈ បាទ!

ខៈ ហើយគាត់រាប់បានមួយអាទិត្យទៀតហើយគាត់ស្លាប់ទៅ។

កៈ គាត់ដឹងអញ្ជឹងម៉ងបង។

ខៈ វាចេះដឹងថាគាត់ហើយចេះតែរាប់ថ្ងៃខែគាត់ម៉ងនិង។

កៈ ហើយអញ្ជឹងគាត់ចេះមើលមែនបង?

ខៈ គាត់ដឹងខ្លួនគាត់ហើយបើតាមគេជឿរតាមសាសនា។

កៈ បាទ!

ខៈ ហើយតាមគាត់និងគាត់ថាគាត់នៅជំនាន់អាពតនិងគាត់ចាប់ជាតិ។

កៈ ចាំជាតិ។

ខៈ ហើយគាត់ដឹងថាគាត់នៅស្រុកណាៗគាត់ចាំ។

កៈ បាទ!

ខៈ ហឺៗ

កៈ គាត់ចាំ។

ខៈ ហើយនិងគាត់ចាំជាតិហើយគាត់ចេះតែប្រាប់គេរហូតទៅហើយគេអត់ជឿរគាត់ទេហើយដល់ពេលអញ្ជឹងទៅបានជឿរគាត់។ហើយដល់ពេលជិតដល់ថ្ងៃស្លាប់និងគាត់ប្រាប់ហើយគាត់អង្គុយហើយគាត់ថាប្រហែលជាម៉ោងពីរកន្លះនិងគាត់ស្លាប់ហើយ។

កៈ បាទ!

ខៈ ហើយយើងអត់ជឿរគាត់ទេ។

កៈ បាទ! អញ្ជឹងដល់ម៉ោងពីរកន្លះគាត់ស្លាប់មែនបង?

ខៈ ហើយគាត់ស្លាប់មែនហើយជឿរគាត់ទៅ។

កៈ ហើយអញ្ជឹងគាត់ដឹងចាំជាតិថាគាត់ស្លាប់នៅម៉ោងពីរកន្លះនិងដែរទៅ។

ខ៖
ហើយជាតិមុខគាត់មិចៗគាត់ប្រាប់ខ្ញុំទាំងអស់និងហើយគ្រាន់និយាយថាពីមុខនិងយើងអត់ជឿរគាត់ហើយអញ្ចឹងយើងអត់ចាំពីសាច់រឿងអត់ដែរមានអញ្ចឹងផងនិង។

ក៖ ហើយអញ្ចឹងបងមានចាំថ្ងៃខែឆ្នាំកំណើតគាត់ទេម្ដាយបងប៉ាបងថាគាត់កើតថ្ងៃណា?

ខ៖
អរខ្ញុំអត់ដឹងខ្ញុំអត់ចាំព្រោះឪពុកខ្ញុំគាត់ទៅបាត់អញ្ចឹងហើយនៅពេលខ្ញុំនៅឆ្ងាយពីគាត់អញ្ចឹងតែបើឲ្យខ្ញុំចាំថាគាត់កើតខ្ញុំអត់ចាំទេហើយបើខ្ញុំជួបមុខគាត់ខ្ញុំចាំ។

ក៖ ហើយអញ្ចឹងបងមានចាំឆ្នាំខ្មែរយើងគាត់ឆ្នាំអីដែរបង?

ខ៖ ហើយបើឆ្នាំខ្មែរម្ដាយខ្ញុំគាត់ឆ្នាំ រកា ។

ក៖ ហើយអញ្ចឹងលោកឪពុកបង?

ខ៖ ឪពុកគាត់ឆ្នាំ មមី ។

ក៖
អរគាត់ឆ្នាំមមីបង។ហើយអញ្ចឹងបងមានដឹងថាគាត់កើតនៅកន្លែងណាទេបង?ហើយស្រុកកំណើតគាត់បងមានចាំទេបងឬគាត់នៅនិងម៉ងបង?

ខ៖
អូរបើឪពុកខ្ញុំគាត់នៅស្រុកជាមួយគ្នានិងហើយពេលគាត់មានម្ដាយខ្ញុំទៅហើយគាត់ទៅស្រុកចំការលើហើយគាត់ស្រុកអែបៗគ្នានិង។

ក៖ អរស្រុកជាប់ៗគ្នា។

ខ៖ និងហើយគាត់នៅស្រុកជាប់ៗគ្នានិង។

ក៖
ហើយអញ្ចឹងបងមានចាំថាពេលដែលលោកឪពុកបងពេលគាត់នៅរស់គាត់ប្រកបមុខរបរអីដើម្បីចិញ្ចឹមបងហើយនិងប្អូនៗបង?

ខ៖
អឺកាលពីគាត់បានត្រលប់មកវិញហើយពេលដែរគាត់បានបែកយើងទៅនិងគាត់បានចិញ្ចឹមយើងទេហើយគាត់តាំងពីខ្ញុំនៅតូចមកហើយពេលនិងខ្ញុំមានអាយុប្រាំពីរឆ្នាំហើយពេលគាត់បានមកវិញនិងគាត់បានចិញ្ចឹមខ្ញុំទេហើយគ្រាន់តែគាត់មានជីវភាពធូរធារដែរ។ហើយគាត់ចេះតែទៅផ្សំថ្នាំទៅមើលជម្ងឺគេនិង។ហើយពេលកន្លងមកគាត់ចេះតែបង្រៀនខ្ញុំហើយខ្ញុំ

ចេះអីទៅហើយខ្ញុំក៏បង្កើតមុខរបរនិងតទៅ។ហើយខ្ញុំបង្កើតមុខរបរសព្វថ្ងៃនិងហើយយើងអត់ចេះហើយយើងថាចេះក៏យើងលក់អត់ដាច់យើងក៏អត់បានថវិកាដែរ។

ក៖ បាទ!

ខ៖ ហើយយើងក៏មិនអាចបានចិញ្ចឹមជីវិតដែល។

ក៖ បាទ!ហើយបងតើគាត់ជាមនុស្សបែកណាដែលបងគាត់កាត់ឬក៏គាត់ស្លូតដែលបង?

ខ៖ ឪពុកខ្ញុំគាត់កាត់ពិនតែគាត់ចិត្តល្អគាត់ចូលចិត្តនិយាយអីត្រង់។

ក៖
បាទ!អ្នកនិយាយត្រង់ភាគច្រើនគេស្ដាប់មកកាត់ណាស់តាមពិតគាត់មិនសូវកាត់ប៉ុន្មានទេ?

ខ៖ ចរិករបស់គាត់ប្រហែលនឹងខ្ញុំដែលនិយាយអីលឺៗចឹងណាស់។

ក៖ បាទ!ចឹងអ្នកម៉ាក់របស់បងវិញ?

ខ៖ ម្ដាយខ្ញុំគាត់អត់មានធ្វើអីទេ។

ក៖ បាទ! អញ្ចឹងអត់ធ្វើស្រែចំការមែនបងកាលណុង?

ខ៖ បាទ!
ពេលខ្លះគាត់ទៅធ្វើចំការគាត់នៅក្រោយផ្ទះនិងទៅហើយគាត់បេះឈូកបេះអីអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងគាត់ទៅបេះឈូកទៅបង។

ខ៖ បាទ!គាត់បេះឈូកលក់ចឹងទៅ។

ក៖ បាទ!គាត់បេះការឈូកចឹងទៅ?

ខ៖
បាទ!គាត់បេះការឈូកចឹងទៅហើយកាលពីមុនគាត់ធ្លាប់លក់បន្លែអីចឹងទៅបានមានតាពិននឹងមិខរបរ
ស្រុកស្រែចំការពិបាកនិយាយទៅវាពិបាកហើយពេលយើងរកពិបាកចឹងទៅយើងមានកាតស៊ូរហើយបើយើងមានការតស៊ូរយើងអត់ពិបាកទេរាល់ថ្ងៃនឹងទល់តែមានការតស៊ូយើងនិយាយទៅនៅក្នុងសង្គមយើងគឺមានការតស៊ូរបើយើងចង់មានម៉ងវាមិនអាចទេហើយបើយើ

ងថាចាំស្អែកមាននេះគេអោយលុយនោះគេអោយលុយអត់មានទេទល់តែយើងមានជីវិត្តរបស់យើងមានការតស៊ូយើងមានការខ្មាស់ខ្មែងទើបយើងបានជោកជ័យ។

ក៖ បាទ!ចឹងតើបងមានចាំថាសាច់រឿងអ្វីខ្លះជាមួយគាត់ការជូរជត់អ្វីខ្លះណាស់បង?

ខ៖
ការជូរជត់មានច្រើនដូចថាធម្មតាខ្ញុំទៅបឹងខ្ញុំទៅអីចឹងទៅមានដូចថាពេលដែលយេញភ្លៀងចឹងខ្ញុំនៅបឹងគាត់ចេះតែស្រែកហៅយើងថាកូននៅណាយើងទូលស្លឹកឈូកដក់ការឈូកអីចឹងទៅគាត់ចេះតែចាំយើងចាំជារៀងរាលថ្ងៃចឹងទៅដល់ទៅគាត់ជួយទូលចឹងទៅមានតាប្អូនខ្ញុំនឹងវានៅស្ទើតូចៗនៅរៀនខ្លះវានៅក្មេងហើយយើងធំខ្ញុំចេះតែប្រឹងទៅខ្ញុំនិយាយទៅម៉ាបងប្អូនខ្ញុំពិបាកជាងគេដោយសារខ្ញុំនិយាយទៅរាប់រងគ្រួសារច្រើនណាស់។

ក៖ បាទ!

ខ៖ វាមិចៗយើងចេះតែរាប់រងគ្រួសារ។

ក៖ បាទ!ណាមួយបងជាមនុស្សប្រុសផង?

ខ៖ បាទ!វាពិបាក។

ក៖ ណាមួយអ្នកម្តាយរបស់បងជាមេម៉ាយផង?

ខ៖
បាទ!ឥឡូវនឹងក៏វានៅមិនទាន់ស្រួលផងពិបាកតែគ្រាន់វាបានមួយចហានៗដែលយើងចេះតែដើរទៅហើយខ្ញុំនៅរាល់ថ្ងៃនឹងម្តាយខ្ញុំគាត់ថាអោយទៅនៅស្រុកវិញទៅតែខ្ញុំមិនដឹងថានៅស្រុកនឹងរកស៊ីអីមានតាដក់ការឈូកយើងនៅនេះទៅរកបានម៉ាសល់លុយដោយសារខ្ញុំចេះតស៊ូទៅ។

ក៖ បាទ!នៅខេត្តបានតែធ្វើស្រែចំការខ្លះអត់ខ្លះមានទៅ?

ខ៖
ដល់ចឹងទៅខ្ញុំរកបានទៅផ្ទះសំបែង១ឆ្នាំទៀតធ្វើនឹងក៏យើងមែនថាយើងមានលុយទាំងដូលធ្វើដែលយើងខ្ចីគេណាស់។

ក៖ បាទ!យើងធ្វើម្តងទិចៗ?

ខ៖ បាទ!យើងខ្ចីគេចឹងទៅឥឡូវយើងខ្ចីគេ៤
៥ឆ្នាំចឹងទៅយើងសងគេហើយណាស់យើងធ្វើទៅយើងសន្សំអីខ្លះទៅយើងចំពាក់គេខ្លះទៅណាស់បើយើងអត់ចេះជំពាក់គេយើងរកវាមិនបានយើងមិនជំពាក់គេសម័យឥឡូវមួយ

ណាដែលអត់ជំពាក់គេបើយើងរកអត់ជំពាកគេមានតាយើងរកមួយរសៗទៅយើងចេះជំពាក់គេទៅយើងចេះតែរកបន្តោះៗទៅវាចេះតែសល់របស់យើងហើយ។

កៈ បាទ!ចឹងបងមានចាំឈ្មោះលោកតលោកយាយរបស់បងទេ?

ខៈ លោកតាលោកយាយខ្ញុំនឹងមែន។

កៈ បាទ!

ខៈ កាលជំនាន់នឹងខ្ញុំចាំតាគាត់ឈ្មោះសំ។

កៈ គុងមែងបង?

ខៈ បាទ!ឪពុកខាងម្តាយខ្ញុំឈ្មោះសំ។

កៈ បាទ!ហើយចុះលោកយាយបង?

ខៈ លោកយាយឈ្មោះ ផេន នឹងខាងម្តាយ។

កៈ បាទ!ចុះលោកឪពុកបងមានចាំទេ?

ខៈ ខាងឪពុកគាត់មានឈ្មោះ គុត ដល់ពេលលោកយាយខ្ញុំគាត់ឈ្មោះ យាយសាន។

កៈ
បាទ!ចឹងបងមានបានដឹងថាពេលនឹងតើគាត់បងមានបានដឹងថាគាត់កើតឆ្នាំអីទេបងដូចជាឆ្នាំខ្មែរយើងអីណាស់បង?

ខៈ ខ្ញុំអត់ចាំទេ។

កៈ បាទ!ចឹងបងអត់ចាំទេបង?

ខៈ
បាទ!ខ្ញុំអត់ចាំទេបើឆ្នាំខ្មែរខ្ញុំស្គាល់ឆ្នាំគាត់នឹងឆ្នាំរោងខាងម្តាយខ្ញុំជីតាខ្ញុំឆ្នាំរោងយាយខ្ញុំឆ្នាំមមីរបាទហើយបើខាងជីតាខ្ញុំមួយទៀតខ្ញុំចាំតាយាយខ្ញុំទេឆ្នាំមមែលបើជីតាខ្ញុំអត់ដឹងថាគាត់ឆ្នាំអីទេព្រោះគាត់ស្លាប់យូរដែលហើយយាយខ្ញុំខាងឪពុកខ្ញុំគាត់ស្លាប់ហើយតែខ្ញុំនៅចាំឈ្មោះគាត់ចាំអាយុគាត់បើជីតាខ្ញុំអត់ចាំទេ។

កៈ បាទ!ចឹងបងមានសាច់ញ្ញាតិខាងម្តាយអីដែលគាត់រស់នៅក្រៅប្រទេសទេបង?

ខៈ និយាយទៅអត់មានទេ។

កៈ អត់មានទេបង?

ខៈ បាទ!គាត់អត់មានទេ។

កៈ បាទ!ចឹងនៅថៃអីបងតើមានទេ?

កៈ
អត់មានទេនៅថៃក៏អត់មានដែលនិយាយទៅនៅក្រៅប្រទេសអត់មានទេនៅស្រុកខ្មែរមាន
។

កៈ
បាទ!ចឹងបងបើនិយាយពីគូរជីវិត្តរបស់បងវិញណាស់តើប្រពន្ធបងមានឈ្មោះអ្វីដែលបង?

ខៈ គាត់មានឈ្មោះ ទូត ។

កៈ បាទ!ចឹងឈ្មោះប្រពន្ធបងមានឈ្មោះ ទូត
ចឹងបងតើនៅពេលដែលបងបានរៀបការជាមួយគាត់នឹងតើបងរៀបការតាំងពីឆ្នាំណាដែល
បង?

ខៈ ខ្ញុំរៀបការនឹងនៅឆ្នាំ២០១២។

កៈ បាទ!ចឹងបងរៀបការជាមួយភរិយាយបងនៅឆ្នាំ២០១២?

ខៈ ឆ្នាំ២០១២ថ្ងៃស្រុកខ្ញុំចង់ភ្លេចហើយព្រោះយូរហើយចង់១០ឆ្នាំហើយ។

កៈ
បាទ!ចឹងបងថាបងពេលនឹងពេលបងបានជួបបងស្រីនឹងបងរៀបការនឹងតើបងជាអ្នកសំរា
ច់ដោយខ្លួនឯងឬក៏លោកឪពុកអ្នកម្តាយបងជាអ្នករៀបចំអោយចឹងណាស់បង?

ខៈ ខ្ញុំស្រលាញ់ដោយខ្លួនឯងទេបានឪពុកម្តាយខ្ញុំគាត់រៀបចំអោយ។

កៈ បាទ!ដល់ពេលបងស្រលាញ់គ្នាហើយបានពួកគាត់រៀបចំអោយបងទៅ?

ខៈ បាទ!

កៈ បាទ!ចឹងបងតើពេលនឹងតើបងជូនចំណងដៃទៅកាន់គាត់ប៉ុន្មានដែលបង?

ខៈ អត់ទេពេលនឹងគាត់ទៅការគាត់ស្រលាញ់គ្នាដោយចិត្តឯង។

កៈ អរគាត់ទៅការម៉េងមិចចាំបាត់ចំណងដៃទេគេការគេហៅអ្នកជិតខាងសែនអីចឹងទៅ?

ខ៖ បាទ!

ក៖
បាទ!ចឹងបងអាចប្រាប់ខ្ញុំបានទេថាដំបូងណាស់នៅពេលដែលបងបានស្គាល់ភរិយាយរបស់បងនឹងតើនៅណាដែលបង?

ខ៖ ខ្ញុំជួបគាត់នឹងនៅភ្នំពេញនឹង។

ក៖ បាទ!ចឹងបងស្គាល់គាត់នៅភ្នំពេញគាត់ធ្វើការបង?

ខ៖
បាទ!គាត់ធ្វើការពេលជួបគាត់នឹងមុនដំបូងមិនទាន់មានចិត្តស្រលាញ់គាត់ទេដល់ពេលរៀងយូរយើងមើចិត្តគាត់ទៅបានយូរទៅបានខ្ញុំស្រលាញ់គាត់។

ក៖
បាទ!ចឹងបងតើបងអាចសរសេរភាសាខ្មែរបានច្រើនទេអានអីណាស់បងតើបងអាចបានទេ?

ខ៖ អរភាសាខ្មែរខ្ញុំចេះច្រើនភាសាខ្មែរខ្ញុំចេះអានខ្ញុំរៀនត្រឹមថ្នាក់ទី៨។

ក៖ អរបងរៀនបានថ្នាក់ទី៨ចប់ថ្នាក់ឌីផ្លោមហើយ។

ខ៖ ហើយត្រឹមថា្នក់ទី៨ហើយខ្ញុំឈប់នៅឆ្នាំ៩៥និងទេ។

ក៖ បាទ!
ហើយអញ្ចឹងបងឈប់នៅឆ្នាំ៩៥។ហើយអញ្ចឹងបងបើនិយាយពីភាសាបរទេសវិញបងមានចេះដូចជាភាសាវៀតណាម ថៃអីទេបង?

ខ៖ អរនិយាយពីភាសា។

ក៖ បាទ! ដូចអង់គ្លេសអីបង?

ខ៖ បើនិយាយឲ្យចំទៅខ្ញុំហើយជំនាន់និងខ្ញុំរៀនបារាំង។

ក៖ អររៀនបារាំង។

ខ៖
នឹងហើយរៀនបារាំងហើយរៀនបានប៉ុន្មាននិងទៅហើយរៀនដល់ថា្នក់និងទៅហើយកាលពីជំនាន់គេរៀនដែរ ដូច A B C D “ អា បេ សេ ដេ “

ហើយកាលនិងណុងខ្ញុំរៀនក៏មិនសូវបានច្បាស់ដែរនិង។ហើយមិនថារៀនដល់កំពូលទេ គ្រាន់តែបានចេះតិចតួចនិង។

ក៖ បាទ! បានតិចតួចនិង។

ខ៖
យើងចេះបានតែពាក្យស្រោលនិងយើងអត់ចេះហើយបើជាភាសាថៃអីហើយខ្ញុំទៅលេងវាបានប្អូនដប់ថ្ងៃខ្ញុំអាចស្តាប់វាបានហើយដូចថាផ្លែអីបានភាសាវែកៗនិង។

ក៖ បាទ!

ខ៖ ដូចថាយើងអាចស្តាប់បានអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
ហើយគេនិយាយប្រាប់យើងថាដើមស្វាយហៅអីហើយអំពៅហៅអីហើយអីអញ្ចឹងទៅហើយបើភាសាអង់គ្លេសខ្ញុំរៀងពិបាកបន្តិចហើយបើភាសាថៃបើខ្ញុំបានចូលរៀននិងខ្ញុំអាចចេះភាសានោះ។ហើយដូចថាយើងមានការភ្លេចភ្លែងច្រើនយើងជំនាស់នេះហើយនិង។

ក៖ បាទ!

ខ៖ បើនៅពីក្មេងនិងខ្ញុំរៀនចេះហើយ។

ក៖ បាទ! បើនៅក្មេងនិងបងអាចចេះបង។

ខ៖
ហើយបើភាសាថៃយើងរៀនឥឡូវនិងយើងអត់ទាន់ហួតពេលទេយើងរៀនឥឡូវយើងអាចចេះបានដែរ។

ក៖ បាទ!

ខ៖ ហើយយើងភាសាថៃបើនិយាយឲ្យចំទៅហើយវានិយាយដូចតែខ្មែរយើងដែរនិង។

ក៖ បាទ!

ខ៖ បាទ! ដូចធម្មតាហៅធម្មតាដូចគ្នាដែរនិង។

កៈ បាទ! ហើយអញ្ចឹងបងបានប្រាប់ខ្ញុំថាបងបានកម្រិតបានត្រឹមថ្នាក់ទីប្រាំបីដែរហើយអញ្ចឹងសាលាបងនៅឯណាបង?

ខៈ នៅនិងដូចថានៅស្រុកនិងតែអូរនិងគេនៅខាងនេះវិញ។

កៈ អូរ! យើងមកឆ្លងទឹកវិញ។

ខៈ វាអត់ឆ្លងទឹកទេវាហួតឡើងទៅលើវិញ។

កៈ បាទ! ទៅលើវិញ។

ខៈ គេហៅហាន់ជ័យៗ ។

កៈ អរ! ហើយអញ្ចឹងសាលានិងមានឈ្មោះអីបង?

ខៈ សាលាមហាវិទ្យាល័យហាន់ជ័យ។

កៈ អូរ! មហាវិទ្យាល័យហាន់ជ័យ។

ខៈ មហាវិទ្យាល័យហាន់ជ័យនិងមុខមិនមែនទៅដល់លើនិងទេហើយនៅក្រោមទេគេហៅមាន់ហើរទេហើយគេបែកទៅហើយគេទៅបង្កើតសាលាមួយទៀតទៅ។

កៈ និងគេធ្វើនៅជង្គេះភ្នំនិងទេបង។

ខៈ នឹងៗហើយមហាវិទ្យាល័យហើយកាលមុខនៅនិងទេ។

កៈ បាទ! កាលមុននៅខាងមាន់ហើរនេះទេ។

ខៈ បាទ!

កៈ ហើយគេលើទៅនិងដូចគេថាមាន់ហើរនិងលិចទឹកបង។

ខៈ បាទ! នឹងហើយខាងនិងមុនលិចទឹក។

កៈ ហើយគេលើកទៅដាក់នៅនិងទៅវាអត់លិចទឹក។

ខៈ បាទ!

កៈ ព្រោះអីវាខ្ពស់ហើយអញ្ចឹងពេលបងនៅរៀននិងបងមានមិត្តភក្តិជិតស្និតទេបង។

ខ៖
មានៗមួយម្នាក់ពីរម្នាក់និងហើយជិតស្និតនិងហើយអត់ស៊ីដូចថាខ្ញុំមកហើយវានៅឆ្ងាយនិង
វាឆ្លងទឹកនិងហើយយកមកចែកគ្នាញ៉ាំទៅ។

ក៖ បាទ! ចែកគ្នាញ៉ាំទៅ។

ខ៖
ហើយថាអញ្ចេកវាហើយឥឡូវនិងវាក្លាយជាឧកញ៉ាជាអ្នកមានហើយដូចថាយើងមិននឹក
ស្មាន់ដល់ណាស់។

ក៖ អរ!

ខ៖ វាមានខ្សែហើយបើយើងនិយាយស្រុកខ្មែរគេហៅខ្សែៗ ។

ក៖ បាទ!

ខ៖
ហើយដល់ពេលវាមានខ្សែវាអ្នកធំទៅហើយវាឡើងមានហើយវាមកតាមពីរបីដងដែរតែយើ
ងអញ្ចេកអញ្ចុះអត់ចងជួបវាព្រោះអីយើងមើលទៅដូចខ្សត់ជាងវាអញ្ចឹងណាស់ហើយគេ
ចេះតែតាមសួរដែរហើយដល់អញ្ចឹងទៅហើយគេចេះមកតាមយើងពីរបីដងដែរហើយគេ
ចេះមកតាមទៅ។ហើយថាយើងរឹកយើងអីមិនមែនទេហើយតាមការពិតយើងវាក្រជាងគេ
យើងខ្ជិលរាប់អានគេទៅហើយខំអីខ្ញុំមានទាល់រាល់ថ្ងៃនិង។

ក៖ បាទ!

ខ៖ ហើយវាមកតាមតាំងពីឆ្នាំ២០០០ហើយប្រហែលឆ្នាំ២០០១ទៅ២០០២។

ក៖ បាទ!

ខ៖
ហើយជំនាន់និងវាមកតាមខ្ញុំណាស់ហើយខ្ញុំដើរគេចពីវាហើយវាដើរតាមរកខ្ញុំហើយតាមសួ
រគេហើយខ្ញុំរ
ត់ទៅពួនវាហើយមានគ្នាវាទៅបួនប្រាំនាក់ហើយវានៅភ្នំពេញនិរាល់ថ្ងៃនិងហើយខ្ញុំស្គាល់ក
ន្លែងប្អូនវានៅនិងតាប៉ុន្តែប្អូនវាចេះតែសួរថាខ្ញុំនិងមិចហើយខ្ញុំថាខ្ញុំនៅផ្ទះជួលអញ្ចឹងណាស់
។

ក៖ បាទ!

ខ៖ តែខ្ញុំអត់ទៅរកគេ។

ក៖ បាទ!

ខ៖ ដូចខ្ញុំមានចិត្តថាចង់តស៊ូខ្លួនឯងទៅ។

ក៖ បាទ! យើងមានចិត្តចងតស៊ូខ្លួនឯងទៅបង។

ខ៖ បាទ! ហើយដូចថាខ្ញុំទិញដីនៅឯនេះដូចថាខ្ញុំហើយយើងតស៊ូទៅហើយយើងតស៊ូបានមួយឆ្នាំអីទៀតទៅយើងបានធ្វើផ្ទះនិងហើយបានមួយឆ្នាំពីរឆ្នាំអីទេយើងបានផ្ទះនៅខ្លួនយើងនិង។ ហើយផ្ទះនេះខ្ញុំជួលមិនដល់បានមួយឆ្នាំពីរឆ្នាំហើយខ្ញុំបានលុយធ្វើផ្ទះទៅខ្ញុំលែងបានជួលទៀតហើយ។

ក៖ បាទ! ហើយអញ្ចឹងបងកាលដែរបងនៅពីក្មេងបានមានធ្លាប់ធ្វើការស៊ីឈ្នួលគេដកស្ទូងធ្វើស្រែធ្វើចំការគេទេបង?

ខ៖ អរកាលនៅពីក្មេងខ្ញុំអត់ដែរស៊ីឈ្នួលដកស្ទូងគេទេបើស៊ីឈ្នួលគេច្រូវស្រូវគេខ្ញុំធ្លាប់ហើយវាយសណ្តែកសៀងនិងខ្ញុំធ្លាប់។

ក៖ បាទ! វាយសណ្តែកសៀងបងធ្លាប់។

ខ៖ បាទ! វាយសណ្តែកសៀងនិងខ្ញុំធ្លាប់ហើយបើស៊ីឈ្នួលគេផុតពីនិងអត់ទេហើយពេលនិងខ្ញុំនៅក្មេងហើយមកដល់ឥឡូវនិងខ្ញុំធំហើយខ្ញុំនឹកឃើញថាខ្ញុំស៊ីឈ្នួលគេនិងវាមិនស្រួលនិងហើយខ្ញុំទៅរកនេះមួយកន្ទប់ហើយនោះមួយកន្ទប់ទៅហើយយើងនិងវាអត់ពិតប្រាកដណាស់។

ក៖ បាទ!

ខ៖ ហើយរកនេះមួយកន្ទប់ទៅហើយទៅរកនេះមួយកន្ទប់ទៅហើយចេះតែបានចេះតែរស់ទៅរាល់ថ្ងៃនិងហើយប្រពន្ធខ្ញុំអត់ធ្វើការប្រហែលជាបីបួនខែហើយខ្ញុំរកនេះមួយតិចទៅហើយរកនោះមួយតិចទៅហើយខ្ញុំថាគ្មានបានហូបអីឆ្ងាញអីទេហើយការមុននិងយើងចេះតែរកបានតិចតួចទៅហើយពេលខ្លះនិងមានការលំបាកណាស់ដែរនិង។ហើយខ្ញុំថាតស៊ូគង់តែបានសម្រេចទេ។

ក៖ បាទ!

ខ៖
ហើយបើថាឲ្យមានម៉ងនិងវាមិនមានទេហើយតស៊ូមួយឈានដល់ថ្ងៃចុងក្រោយនិងហើយបើចាំថាមានវាគ្មានទេ។

ក៖ បាទ! ថ្ងៃណាមានបើមិនខំប្រឹង។

ខ៖ ហើយអញ្ចេកបើយើងស្គាល់អ្នកដែរស្គាល់យើងហើយឃើញគេមានកុំបាក់ស្មារតី។

ក៖ បាទ!

ខ៖ ហើយយើងកុំមើលឃើញគេទៅលើណាស់។

ក៖ បាទ!

ខ៖ ហើយយើងមើលចុះមកក្រោមសិន។

ក៖ បាទ!

ខ៖ ហើយរូបយើងកំពុងធ្វើអី។

ក៖ បាទ!

ខ៖
ហើយយើងសម្លឹងមើលថាហើយឡើងតិចទៀតទៅយើងមើលទៅលើមេឃហើយគេចេះតែខ្ពស់ទៅៗហើយមានការខ្មាស់គេកុំថាខ្មាស់គេនិងចប់ហើយ។ហើយយើងថាអញថ្ងៃនិងរកស៊ីបានប៉ុណ្ណឹងហើយស្អែកអញរកស៊ីបានច្រើនជាងនេះ
ទៀតហើយយើងមើលកម្រិតយើងតិចៗហើយយើងមើលសម្ថតភាពរបស់យើង។

ក៖ បាទ!

ខ៖ ហើយយើងធ្វើអីលើសពីសម្ថតភាពរបស់យើងនិងហើយក៏យើងអត់ទៅអត់រួចដែរ។

ក៖ បាទ! ក៏ពិបាកដែរ។

ខ៖ នឹងហើយនិងពិបាកហើយ។ព្រោះអីយើងត្រូវមានសម្ថតភាពយើងមានលំនឹងសិន។

ក៖ បាទ!

ខ៖
ហើយបើយើងគិតថាយើងមានសម្ថតភាពខ្ពស់ជាងនិងទៅទៀតទៅ។ហើយធ្វើការងារអីក៏

ដោយឲ្យហើយការរកស៊ីអីក៏ដោយបើយើងធ្វើអីលើសពីសម្តតភាពយើងនិងយើងនិងធ្លាក់មកហើយ។

ក៖ បាទ!

ខ៖ ហើយថាយើងធ្លាក់ហើយយើងលំបាកហើយ។ហើយបើនេះទេយើងរកនឹងៗរហូតទៅណាស់ហើយមនុស្សណាក៏មានសម្តតភាពដែរហើយការលោភលន់យើងកុំមានការលោភលន់ពេក។

ក៖ បាទ! មានច្រើនការលោភលន់និងអាចធ្លាក់បាន។

ខ៖ នឹងហើយបើយើងមានការលោភលន់ពេកយើងពិបាកហើយ។

ក៖ បាទ!

ខ៖ ហើយនិងយើងមានមហិតានៅក្នុងខ្លួននិងតែងតែមានចិត្តមួយចេះតែមួរម៉ងនៅដេកផ្ទះនៅមិនសុខនិង។

ក៖ បាទ! ហើយអញ្ចឹងបងតាំងពីក្មេងរហូតបងដល់ធំនិងបងមានការផ្លាស់ប្តូរច្រើនទេបង?

ខ៖ បើតាំងពីតូចរហូតដល់ធំនិងខ្ញុំមានការផ្លាស់ប្តូរច្រើននៅក្នុងជីវិតពីមួយទៅមួយឆាកជីវិតលំបាកយ៉ាងមិចអញ្ចឹងណាស់ហើយយើងចេះតែផ្លាស់ប្តូរពីដកក្របប្អារឈូកមកលក់ថ្នាំប៉ុន្តែហើយសិនអាជីពលក់ថ្នាំនេះខ្ញុំមិនអាចចោលបានទេ។

ក៖ បាទ! ជាឆ្នាំងបាយយើងបង?

ខ៖ បាទ! ណាមួយវាជាឆ្នាំងបាយយើងហើយវាជា។

ក៖ ការបន្តវេន។

ខ៖ បាទ! ការបន្តវេនដែរហើយពីបុរាណខ្មែរយើងដែរ។

ក៖ បាទ!

ខ៖ ដូចខ្មែរយើងមិនអាចបាត់បង់ហើយអ្នកខ្លះហើយគេចេះតែនិយាយថាថ្នាំខ្មែរថៃសចុះអីថា

ហើយផឹកទៅវាមានជ័រមានអីហើយតាមការពិតខ្ញុំស្រាវជ្រាវថ្នាំខ្មែរមករហូតនិងហើយអត់មានជាតិហើយថ្នាំយើងទោះពេទ្យឥឡូវក៏ធ្វើពីថ្នាំខ្មែរដែរ។

ក៖ បាទ! គេយកដើមឈើមកធ្វើថ្នាំដែរនិង។

ខ៖ បាទ!
គេយកថ្នាំខ្មែរយើងនិងមកធ្វើថ្នាំដែរនិងហើយបានថាថ្នាំខ្មែរមួយថាជាវត្ថុមួយគេហៅថាវត្ថុធាតុដើម។

ក៖ បាទ! ជាវត្ថុធាតុដើមនិង។

ខ៖ បាទ!
ហើយខ្ញុំមានទៅដាក់គីមីអីណាទេហើយរាល់ថ្ងៃនិងខ្ញុំលក់ថ្នាំបណ្តើរហើយខ្ញុំទៅព្យាបាលគេបណ្តើរនិង។

ក៖ បាទ!

ខ៖ បាទ!
មុននិងខ្ញុំលក់ថ្នាំដាច់រាល់ថ្ងៃនិងដោយសារខ្ញុំទៅព្យាបាលគេហើយមុនដំបូងនិងអត់យកលុយគេទេ។

ក៖ បាទ!

ខ៖ ព្យាបាលគេអត់យកលុយគេទេហើយគេឲ្យបានមួយបាយហូបទេ។

ក៖ បាទ!

ខ៖ ដូចថាយើងទៅព្យាបាលគេអញ្ចឹងទៅហើយគេឲ្យថ្លៃសាំងបីបួនប្រាំម៉ឺនអីអញ្ចឹងអី។

ក៖ បាទ!

ខ៖ មកឲ្យយើងអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
ជូនយើងហើយដល់ពេលស្គាល់យូរទៅហើយគេដាក់ថាគ្រូមើលជានិងគ្រូយកប៉ុន្មានហើយគេអ្នកឈឺនិងគេមានសម្ថតភាពតែប៉ុណោះ។ហើយដូចមាន៥០ម៉ឺនអីអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយអ្នកខ្លះគេថាមាន៨០ម៉ឺនអីអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
ហើយខ្ញុំថាអាចមើលជម្ងឺបានហើយមើលទាល់រាល់ថ្ងៃនិង។ហើយពីមុនហើយខ្ញុំនៅមានអាជីពនិងរាល់ថ្ងៃនិងហើយបើខ្ញុំចាស់ទៅហើយក្នុងដប់ម្ភៃឆ្នាំអីទៀតក៏ខ្ញុំអត់បោះបង់ចោលដែរ។

ក៖ បាទ!

ខ៖ អត់បោះបង់ចោលដែរ។

ក៖ បាទ! ហើយអញ្ចឹងបងបើនិយាយពីម្ហូបបងចូលចិត្តម្ហូបអីជាងគេបង?

ខ៖ អរម្ហូបហោស?

ក៖ បាទ!

ខ៖ បើតាមម្ហូបខ្ញុំចូលចិត្តជាងគេខ្ញុំចូលចិត្តម្ហូបម្ជូលគ្រឿង។

ក៖ បងចូលចិត្តម្ជូលគ្រឿងបងហើយម្ជូលប្រលឹតអីបង?

ខ៖ បាទ !នឹងម្ជូលប្រលឹតនិងអត់សូវទេខ្ញុំចូលចិត្តម្ជូលគ្រឿងជាងគេ។

ក៖ បាទ! តែម្ជូលគ្រឿងទេ។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងបងល្បែងប្រជាប្រិយវិញដូចជាល្បែងបោះអង្គុញ ទាញព្រ័ត្ត ចោលឈូង លាក់កន្សែងអីបងចូលចិត្តទេ?

ខ៖ បាទ!

ក៖ ពេលចូលឆ្នាំខ្មែរអីអញ្ចឹងណាស់។

ខ៖ បាទ! បើនិយាយហើយបើនិយាយឲ្យចំទៅខ្ញុំចូលចិត្តជាងគេចោលឈូង។

ក៖ ចោលឈូងបងហើយអញ្ចឹងបោះអង្គុញអត់ចូលចិត្តទេបង?

ខ៖ ហើយបោះអង្គុញអត់សូវប្រសប់លេងទេ។

កៈ បាទ! ហើយអញ្ចឹងបងចូលចិត្តរាំទេបង?

ខៈ ហើយបើរាំចូលចិត្តដែរនិង។

កៈ ហើយអញ្ចឹងបងចូលចិត្តរាំច្រៀងដែរបង?

ខៈ បាទ! ខ្ញុំចូលចិត្តរាំច្រៀងដែរនិងហើយដូចជាកីឡាប្រដាល់ខ្ញុំអត់ចូលចិត្តទេ។

កៈ បាទ!

ខៈ ហើយខ្ញុំចូលចិត្តជាងគេគឺរាំហើយនិងច្រៀងនិងម៉ងហើយពេលចូលចិត្តគឺច្រៀង។

កៈ ចំរៀងនិងបង។

ខៈ បាទ! ចំរៀងនិង។ហើយបើនិយាយទៅខ្ញុំចូលចិត្តចំរៀងពីសម័យមុន។

កៈ បាទ!

ខៈ
ហើយបើសម័យឥឡូវអត់ដឹងថាច្រៀងថាមិចខ្ញុំស្តាប់អត់យល់អត់ដឹងមិចទេហើយអត់ដឹងថាច្រៀងពីអីនិងហើយបទពីមុននិងថាស្តាប់ទៅថាពិរោះអីអញ្ចឹងណាស់។

កៈ បាទ!

ខៈ ហើយបើបទឥឡូវស្តាប់អត់យល់អត់ដឹងថាមិចអញ្ចឹងណាស់។

កៈ បាទ! ហើយបទពីដើមបងចូលចិត្តបង។

ខៈ បាទ! អត់ដឹងមិច។

កៈ បាទ! បើទីងទុងៗ។

ខៈ នឹងហើយ។

កៈ
ហើយអញ្ចឹងបងដូចអ្នកនៅក្នុងគ្រួសារបងឬមិត្តភក្តិរបស់បងនិងមានអ្នកណាគេចេះលេងឧបករណ៍តន្ត្រីទេបង?ដូចជាស្គរ រណាត ហ្គីតា ព្យាណូ អីមានទេ។

ខៈ អរពីមិត្តភក្តិ។

កៈ បាទ! មិត្តភក្តិហើយនិងក្រុមគ្រួសារបង។

ខ៖ អត់មានគាត់ចេះសោះ។

ក៖ អត់មានទេបង។

ខ៖ អូរមានតែចេះឪពុកមាខ្ញុំ។

ក៖ ឪពុកមាបង។

ខ៖ តែគាត់ចាស់ហើយគាត់ជាច្រៀងតាមអក់ហ្កេស លេងភ្លេងនិង។

ក៖ គាត់ចេះលេងអីខ្លះបងដូចជាស្គរ ហ្គីតា អីគាត់មានចេះទេបង?

ខ៖ ហើយគាត់ចូលចិត្តណាស់ហើយគាត់ជាអ្នកចំរៀងតាមអក់ហ្កេសហើយគាត់លេងភ្លេងអីអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយមួយទៀតឪពុកធំខ្ញុំនិងគាត់ចេះដេញជីហ្វេដែរឪពុកធំនិងគាត់ស្លាប់ហើយ។

ក៖ បាទ!

ខ៖ គាត់ចេះដេញជីហ្វេតែគាត់បង្រៀនខ្ញុំដែរតែខ្ញុំគ្មានដុងហើយរៀនអត់ចេះទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងបងបានប្រាប់ខ្ញុំថាបងបានបន្តវេនពីឪពុករបស់ការផ្សំថ្នាំបង។

ខ៖ បាទ!

ក៖ ហើយក្រៅពីផ្សំថ្នាំបងមានចេះអីទៀតទេបង?

ខ៖ ហើយបើនិយាយអីក្រៅពីផ្សំថ្នាំព្យាបាលជម្ងឺនិងខ្ញុំអត់ចេះអីទេ។

ក៖ បាទ! បងអត់ចេះអីទៀតទេបង។

ខ៖ ចេះដែរដូចថាយើងរកស៊ីអីតិចៗយើងចេះហើយណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយនិងជាមុខរបរហើយជាអាជីពរបស់យើងហើយក្រៅពីមើលជម្ងឺនិងហើយក្រៅពីនិងអត់ចេះទេ។

ក៖ អត់ចេះទេបង។

ខ៖ បាទ! អត់ចេះទេហើយបើផ្សេងៗនិងយើងចេះរកស៊ីអីនិង។

ក៖ បាទ!

ខ៖ ហើយយើងបានរកស៊ីអីតិចនិងខ្ញុំចេះ។

ក៖
ហើយអញ្ចឹងបងដូចតាំងពីតូចរហូតដល់ធំនិងហើយពេលដែលបងបានចូលរៀនអញ្ចឹងណាស់ដូចបងមានក្តីស្រមៃថាពេលដែររៀនចប់និងបងចង់ធ្វើគ្រូបង្រៀន គ្រូពេទ្យ ទាហាន ប៉ូលិសអីទៅបង?

ខ៖ ហើយខ្ញុំពីក្មេងនិងនៅស្រមៃថាចង់ធ្វើគ្រូបង្រៀន
ប៉ូលិសដែរហើយដល់ពេលដែរអញ្ចឹងទៅខ្ញុំ។

ក៖ បាទ! មានក្តីស្រមៃចង់ធ្វើដែរ។

ខ៖
ហើយក្តីស្រមៃនិងដែរហើយខ្ញុំមានមិត្តភក្តិខ្ញុំមួយគេមកហៅខ្ញុំសាកល្បងថាចូលធ្វើការនៅក្នុងផ្សារនិងដែរ។

ក៖ ធ្វើខាងអ្នកយាមកង់យាមម៉ូតូមែនបង?

ខ៖ ហើយដូចគេឲ្យយើងមើលខាងទីផ្សារអីអញ្ចឹង។

ក៖ បាទ! ដើរយកប្រស៊ី។

ខ៖ បាទ!
ប្រស៊ីកាលណុងខ្ញុំនៅធ្វើការនៅណុងតែថាយើងគេឲ្យសាំមអីអញ្ចឹងទៅគេឲ្យយើងធ្វើប៉ូលិសអីអញ្ចឹងទៅណាស់។

ក៖ បាទ!

ខ៖
ហើយគេឲ្យខ្ញុំធ្វើយាមសាលាក្រុងហើយធ្វើយូរទៅកាលពេលនិងបានប្រាក់ខែ៨ម៉ឺនអីនិង។

ក៖ បាទ!

ខ៖ ហើយអញ្ចឹងទៅខ្ញុំខ្ជិលធ្វើទៅ។

កៈ បាទ! បង។

ខៈ ហើយកាលណុងគេបញ្ជូនទៅផ្លូវភ្លោះអូរឫស្សី។

កៈ បាទ!

ខៈ ហើយគេមានមេគេនៅនិងហើយខ្ញុំខ្ជិលធ្វើហើយប្រាក់ខែកាលនិង៨ម៉ឺននិង។

កៈ បាទ! តែឥឡូវ១លានជាងបង។

ខៈ អត់ទេ១លានជាងមកបូកជំនាន់និងមិនលើសគ្នាប៉ុន្មានទេ។

កៈ បាទ! ពេលនិងវាថ្លៃ។

ខៈ ហើយឥឡូវដូចវាបានថ្លៃហើយខុសគ្នាបន្តិចនិង។

កៈ
ហើយអញ្ចឹងបងមានពាក្យអីជាចុងក្រោយថាកុំធ្វើតម្រាបតាមបងអញ្ចឹងពេលបងមានកូន ហើយគាត់ខិតខំរៀនសូត្រអញ្ចឹងបង?

ខៈ
ហើយជាចុងក្រោយនិងចង់ផ្តាំផ្ញើរទៅក្មេងជំនាន់ក្រោយនិងខំប្រឹងរៀនសូត្រទៅកុំឲ្យដូចពូ អញ្ចឹងណាស់។

កៈ បាទ!

ខៈ ហើយឲ្យក្មេងៗខំប្រឹងតស៊ូទៅ។

កៈ ហើយអញ្ចឹងជាចុងក្រោយនិងបងចង់ឲ្យគាត់ជៀសវាងអញ្ចឹងអីគេដែរបង?

ខៈ ឲ្យជៀសវាងអីទេឲ្យជៀសវាងពីគ្រឿងញៀននិង។

កៈ ហើយបងធំបងតូចអីអញ្ចឹងណាស់។

ខៈ បាទ! និងហើយបងតូចបងធំនិងហើយ។

កៈ
ហើយអញ្ចឹងជាចុងក្រោយខ្ញុំសូមអរគុណបងដែរបងបានអនុញ្ញាតឲ្យខ្ញុំធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់បងហើយជីវប្រវត្តិរបស់បងខ្ញុំបញ្ជូនទៅសាលានៅអាមេរិចបង។ហើយអញ្ចឹងខ្ញុំ សូមអរគុណបង។